# ព្រះរាជក្រឹត្យ

នស / រកត /០៧០១/២៣៧

ស្តីពី

## ការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង
## របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ /០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០១៩៩ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្ដីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន និងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ សំដៅបង្កើនប្រសិទ្ធភាពក្នុងការដឹកនាំបញ្ជាកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** ក្រោមព្រះមហាក្សត្រ ដែលជាមេបញ្ជាការកំពូល នៃកងយោធពលខេមរភូមិន្ទ អគ្គមេបញ្ជាការ គឺជាអ្នកដែលមានសមត្ថកិច្ចក្នុងការបញ្ជាកងយោធពលខេមរភូមិន្ទទាំងមូល និងជាអ្នកទទួលខុសត្រូវចាត់តាំង៚.

អនុវត្តភារកិច្ចការពារជាតិរបស់រាជរដ្ឋាភិបាល សំដៅរក្សាអោយបាននូវឯករាជ្យ អធិបតេយ្យភាព សន្តិភាព ស្ថេរភាព សេរីភាព លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងបូរណភាពដែនដីទាំងមូល នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ :** រចនាសម្ព័ន្ធចាត់តាំង តួនាទី ភារកិច្ចរបស់អគ្គសេនាធិការ និងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ដែលមានកន្លងមក ត្រូវបានកែសំរួលដោយរួមបញ្ចូលគ្នា បង្កើតជាអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទតែមួយ ដឹកនាំគ្រប់គ្រង និងបញ្ជាដោយអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ដែលអមដោយអគ្គមេបញ្ជាការរង ដោយមាននាយសេនាធិការចំរុះ និងនាយរងសេនាធិការចំរុះមួយចំនួនធ្វើជាសេនាធិការ មានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម :

ក- អគ្គបញ្ជាការដ្ឋានរួមមាន :

- ខុទ្ទកាល័យ
- អធិការដ្ឋាន
- នាយកដ្ឋានស្រាវជ្រាវចារកិច្ច
- មជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា
- ទីចាត់ការបុគ្គលិក
- ទីចាត់ការកលយុទ្ធ
- ទីចាត់ការចលនូបត្ថម្ភ
- ទីចាត់ការឃោសនា និងពត៌មាន
- ទីចាត់ការហិរញ្ញ

ព្រមទាំងបណ្តាបញ្ជាការដ្ឋានទ័ពជំនាញ បណ្តាទីចាត់ការ បណ្តាសាលា និងកងឯកភាពអន្តរាគមន៍មួយចំនួនទៀត ។

ខ- បញ្ជាការដ្ឋានកងទ័ពជើងគោក

គ- បញ្ជាការដ្ឋានកងទ័ពជើងទឹក

ឃ- បញ្ជាការដ្ឋានកងទ័ពជើងអាកាស

ក្រៅពីនេះ អគ្គមេបញ្ជាការអាចមានទីប្រឹក្សាមួយចំនួនទៀត ដើម្បីជាជំនួយការងារ ។

**មាត្រា ៤ :** មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងទឹក មេបញ្ជាការកងទ័ពជើងអាកាស ដែលមានមេបញ្ជាការរងមួយចំនួនជាជំនួយការ ជាអ្នកទទួលខុសត្រូវចំពោះមុខ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ក្នុងការដឹកនាំ គ្រប់គ្រង និងបញ្ជាកងទ័ពតាមប្រភេទទ័ពរៀងៗខ្លួន ។

**មាត្រា ៥ :** ប្រគល់ជូនអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ នូវតួនាទីក្នុងការកំណត់រចនាសម្ព័ន្ធចាត់តាំង និងភារកិច្ចលំអិតជាក់ស្តែងនៃអគ្គបញ្ជាការដ្ឋាន និងបញ្ជាការដ្ឋាន នៃប្រភេទទ័ពនីមួយៗ ព្រមទាំងតួនាទីក្នុងការរៀបចំស្នើតែងតាំង និងដំឡើងឋានន្តរសក្តិនាយទាហាន តាមស្ថាប័ននានា ចំណុះអគ្គបញ្ជាការដ្ឋានដូចមានចែងក្នុងមាត្រា ៣ ខាងលើ ។ល។

**មាត្រា ៦** : សមត្ថកិច្ចក្នុងការតែងតាំង និងផ្លាស់ប្តូរមុខតំណែងនាយទាហានចំណុះអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម :

ក- អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង នាយសេនាធិការចំរុះ មេបញ្ជាការកងទ័ពជើងគោក ត្រូវបានតែងតាំង និងផ្លាស់ប្តូរមុខតំណែង ដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

ខ- នាយរងសេនាធិការចំរុះ មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការ មេបញ្ជាការរងកងទ័ពជើងទឹក មេបញ្ជាការ មេបញ្ជាការរងកងទ័ពជើងអាកាស មេបញ្ជាការ មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការ មេបញ្ជាការរងយោធភូមិភាគ ទីប្រឹក្សាអគ្គមេបញ្ជាការ នាយក នាយកដ្ឋាន នាយកទីចាត់ការ នាយករងទីចាត់ការ នាយ នាយរងស្ថាប័ន និងមុខតំណែងដទៃទៀត នៅតាមស្ថាប័ន និងកងឯកភាពចំណុះអគ្គបញ្ជាការដ្ឋាន ដែលមានឋានន្តរសក្តិ ចាប់ពីថ្នាក់វរសេនីយ៍ឯកឡើងទៅ ត្រូវបានតែងតាំង និងផ្លាស់ប្តូរមុខតំណែងដោយអនុក្រឹត្យ ។

គ- ក្រៅពីមុខតំណែងដែលបានរៀបរាប់ក្នុងចំណុច ក និង ខ ចំពោះនាយទាហានដែលមានឋានន្តរសក្តិចាប់ពីថ្នាក់វរសេនីយ៍ទោចុះក្រោម ត្រូវបានតែងតាំង និងផ្លាស់ប្តូរមុខតំណែងដោយសេចក្តីសំរេចរបស់អគ្គមេបញ្ជាការ តាមសំណើរបស់មេបញ្ជាការប្រភេទទ័ពនីមួយៗ ប្រធានស្ថាប័ន និងកងឯកភាពចំណុះអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៧** : ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ និងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៩** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។ល។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១*

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១៤៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] សាន